# បុត្រីនៃព្រះ

អែលឌើរ អិម រ័សុល បាឡឺដ
នៃក្រុមសាវក 12 នាក់

*គ្មានតួនាទីណានៅក្នុងជីវិតដែលចាំបាច់ ហើយកាន់តែអស់កល្បជានិច្ចជាងតួនាទីរបស់ភាពជាមាតានោះទេ ។*

បងប្អូនប្រុសស្រីទាំងឡាយថ្មីៗនេះភរិយារបស់ខ្ញុំ បាបារ៉ា បានធ្វើការវះកាត់ខ្នង ហើយពុំអាចងើបចុះឡើង បត់បែន ឬពត់ពែនខ្លួននោះទេ។ ជាញឹកញាប់ ខ្ញុំបានធ្វើការលើកទុកដាក់ បត់បែន និងពត់ខ្លួនជាងច្រើនជាខ្ញុំធ្លាប់ធ្វើពីមុន--- ហើយការធ្វើបែបនោះបានធ្វើឱ្យខ្ញុំកាន់តែថ្លែងអំណរគុណដល់អ្វីដែលស្ត្រី ហើយជាពិសេសអ្នកទាំងអស់គ្នាដែលម្ដាយ បានធ្វើជារៀងរាល់ថ្ងៃ នៅផ្ទះរបស់យើង ។

ទោះបីជាស្ត្រីរស់នៅក្នុងផ្ទះក្រោមកាលៈទេសៈខុសគ្នាជាច្រើនក្ដី---បានរៀបការហើយ នៅលីវ ស្ត្រីមេម៉ាយ ឬត្រូវបានលែងលះ ស្ត្រីខ្លះមានកូនចៅ ហើយខ្លះទៀតគ្មានកូនចៅ---ស្ត្រីទាំងអស់គឺជាមនុស្សសំណប់របស់ព្រះ ហើយទ្រង់មានផែនការសំរាប់បុត្រីដ៏សុចរិតរបស់ទ្រង់ ដើម្បីទទួលពរជ័យដ៏ខ្ពស់បំផុតនៃជោគវាសនា ។

នៅរសៀលនេះ ខ្ញុំចង់ផ្ដោតយកចិត្តទុកដាក់ទៅលើសុន្ទរកថារបស់ខ្ញុំជាចម្បងទៅលើភាពជាម្ដាយ ជាពិសេសចំពោះម្ដាយវ័យក្មេងទាំងឡាយ ។

កាលពីជាឪពុកវ័យក្មេង ខ្ញុំបានរៀនថា តួនាទីនៃការពឹងពាក់គ្នានៃភាពជាម្ដាយ ។ ខ្ញុំបានបំរើជាទីប្រឹក្សា ហើយបន្ទាប់មក ជាប៊ីស្សពអស់រយៈពេល 10 ឆ្នាំ។ នៅអំឡុងពេលនោះ យើងត្រូវបានប្រទានពរជ័យជាមួយនឹងកូនប្រាំមួយនាក់នៃកូនទាំងប្រាំពីរនាក់របស់យើង ។ ជាញឹកញាប់ បាបារ៉ា អស់កម្លាំងខ្លាំងណាស់នៅពេលដែលខ្ញុំទៅដល់ផ្ទះ នៅល្ងាចថ្ងៃអាទិត្យ ។ នាងបានព្យាយាមពន្យល់ពីអារម្មណ៍របស់នាងដែលអង្គុយនៅកៅអីជួរខាងក្រោម នៅម៉ោងប្រជុំសាក្រាម៉ង់ជាមួយនឹងក្រុមគ្រួសារវ័យក្មេងរបស់យើង ។ ហើយបន្ទាប់មកដល់ថ្ងៃដែលខ្ញុំត្រូវដោះលែងពីមុខងាររបស់ខ្ញុំ។ បន្ទាប់ពីអង្គុយនៅលើវេទិកាអស់ 10 ឆ្នាំ ហើយឥឡូវនេះខ្ញុំអង្គុយជាមួយក្រុមគ្រួសាររបស់ខ្ញុំនៅជួរខាងក្រោយ ។

ពួកម្ដាយៗនៅក្នុងវួដត្រូវឡើងច្រៀងចំរៀង ហើយខ្ញុំឃើញថា ខ្ញុំកំពុងតែអង្គុយម្នាក់ឯង ជាមួយកូនប្រាំមួយនាក់របស់យើង ។ ខ្ញុំមិនដែលរវល់ខ្លាំងនៅក្នុងជីវិតរបស់ខ្ញុំទាំងមូល ។ ខ្ញុំមានរូបល្ខោនអាយ៉ងនៅក្នុងដៃទាំងពីររបស់ខ្ញុំ ហើយល្ខោនអាយ៉ងនោះមិនគួរឱ្យចាប់អារម្មណ៍នោះទេ។ នំឈៀរីអូស តែងតែកំពប់លើខ្លួនរបស់ខ្ញុំ ហើយនោះគឺជារឿងគួរឱ្យខ្មាស់អៀនអាស់ ។ សៀវភៅផាត់ពណ៌ហាក់ដូចជាមិនគួរឱ្យចាប់អារម្មណ៍ផងដែរចំពោះពួកគេ ។

នៅពេលដែលខ្ញុំស្មុគស្មាញជាមួយនឹងកូនៗរបស់ខ្ញុំរហូតដល់ការប្រជុំចប់ ខ្ញុំបានសម្លឹងមើល បាបារ៉ា ហើយនាងបាននៅទីនោះទាំងញញឹម ។ ខ្ញុំបានរៀនដោយខ្លួនឯងចំពោះអំណរគុណយ៉ាងខ្លាំងនូវអ្វីដែល អ្នករាល់គ្នាដែលជាម្ដាយជាទីស្រឡាញ់បានធ្វើយ៉ាងល្អដូច្នេះ ហើយពោរពេញដោយសេចក្ដីស្មោះត្រង់!

មួយជំនាន់ក្រោយមក ក្នុងនាមជាលោកតាម្នាក់ ខ្ញុំបានមើលឃើញចំពោះការពលិកម្មរបស់កូនស្រីៗរបស់ខ្ញុំ បានធ្វើនៅក្នុងការចិញ្ចឹមបីបាច់កូនចៅរបស់ពួកគេ។ ហើយឥឡូវនេះ កើតមានមួយជំនាន់ទៀតហើយ ខ្ញុំកំពុងតែមើលដោយអស់សំណើចនូវសម្ពាធនៅលើចៅៗរបស់ខ្ញុំ នៅពេលដែលពួកគេដឹកនាំកូនចៅរបស់ពួកគេនៅក្នុងពិភពលោក

ដ៏រវល់ និងមានសេចក្តីត្រូវការនេះ ។

បន្ទាប់ពីការសង្កេតមើល និងការបញ្ជាក់ពីជំនាន់ទាំងបីនៃម្តាយ ហើយគិតអំពីម្តាយជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំដឹងយ៉ាងប្រាកដថា គ្មានតួនាទីណានៅក្នុងជីវិត ដែលចាំបាច់ ហើយកាន់តែអស់កល្បជានិច្ចជាងតួនាទីរបស់ភាពជាមាតានោះ ទេ ។

*គ្មាន* ផ្លូវដែលល្អឥតខ្ចោះដើម្បីធ្វើជាម្តាយល្អនោះទេ ។ រាល់ស្ថានភាពនីមួយៗគឺពិសេស ។ ម្តាយគ្រប់រូបមានឧបសគ្គខុសៗគ្នា មានជំនាញ និងសមត្ថភាពខុសៗគ្នា ហើយកូនចៅៗខុសគ្នាយ៉ាងប្រាកដ ។ ជំរើសគឺខុសគ្នា ហើយពិសេសសំរាប់ម្តាយគ្រប់រូប និងគ្រប់ក្រុមគ្រួសារ ។ ម្តាយជាច្រើនអាច "បំពេញការងារជាម្តាយពេញម៉ោង" យ៉ាងហោចណាស់នៅអំឡុងពេលអភិវឌ្ឍនៃជីវិតរបស់កូនៗដែរ ហើយម្តាយដទៃជាច្រើនទៀតក៏ដូច្នោះដែរ ។ ម្តាយខ្លះប្រហែលជាត្រូវធ្វើការក្រៅម៉ោង ឬពេញម៉ោង ម្តាយខ្លះទៀតប្រហែលជាធ្វើការនៅផ្ទះ ម្តាយខ្លះទៀតប្រហែលជាបែងចែកជីវិតរបស់នាងជាអំឡុងពេលនៅផ្ទះ និងគ្រួសារ ហើយការងារ ។ អ្វីដែលសំខាន់គឺថាម្តាយស្រឡាញ់កូនចៅរបស់នាងយ៉ាងខ្លាំង ហើយរក្សានូវការពលិកម្មដែលនាងមានសំរាប់ព្រះ និងស្វាមីរបស់នាង បានដាក់អទិភាពលើកិច្ចការទាំងនេះលើកិច្ចផ្សេងៗទៀត ។

ខ្ញុំមានការស្ងប់ស្ងែងចំពោះម្តាយជាច្រើនដែលបានរៀន ថាតើវាសំខាន់ប៉ុណ្ណាក្នុងការផ្តោតយកចិត្តទុកដាក់ទៅលើកិច្ចការដែលអាចធ្វើឡើងបានតាមតែរដូវកាលជាក់លាក់នៃជីវិតប៉ុណ្ណោះ ។ បើកូនម្នាក់រស់នៅជាមួយឪពុកម្តាយអស់រយៈពេល 18 ឬ 19 ឆ្នាំរយៈពេលនោះគឺជារយៈពេលមួយភាគបួននៃជីវិតរបស់ឪពុកម្តាយប៉ុណ្ណោះ ។ ហើយជាពេលដ៏រីកចំរើន បំផុតជាងពេលណាៗទាំងអស់ ការចាប់ផ្តើមនៃជីវិតរបស់កូនម្នាក់ តំណាងឱ្យតិចជាងមួយភាគដប់នៃជីវិតមតៈរបស់ពួកគេ ។ វាសំខាន់ណាស់ក្នុងការផ្តោតយកចិត្តទុកដាក់ទៅលើកូនចៅរបស់យើងអស់មួយរយៈខ្លី យើងមានពួកគេនៅជាមួយយើង ហើយត្រូវស្វែងរកជំនួយពីព្រះអម្ចាស់ ដើម្បីបង្រៀនពួកគេនូវអ្វីៗដែលយើងអាចធ្វើបាន ពីមុនពួកគេចាកចេញពីផ្ទះរបស់យើង ។ កិច្ចការដ៏សំខាន់នៅអស់កល្បជានិច្ចនេះ ធ្លាក់ទៅលើម្តាយ និងឪពុកទាំងឡាយជាដៃគូស្មើភាពគ្នា ។ ខ្ញុំមានអំណរគុណដែលឪពុកជាច្រើន ដែលកាន់តែចូលរួមចំណែកនៅក្នុងការថែទាំកូនចៅរបស់ពួកគេ ។ ប៉ុន្តែខ្ញុំជឿថាសភាវគតិ និងប្រពលភាពនៃការចិញ្ចឹមបីបាច់ដែលទាក់ទងនឹងម្តាយទាំងឡាយ ជាមួយនឹងកូនចៅរបស់ពួកគេនឹងតែងតែជាចំនុចសំខាន់ចំពោះសុខុមាលភាពនៃកូនចៅរបស់ពួកគេជានិច្ច ។ នៅក្នុងពាក្យសំដីនៃ ការប្រកាសអំពីក្រុមគ្រួសារបានសរសេរថា: "ម្តាយមានកាតព្វកិច្ចពិសិដ្ឋក្នុងការថែរក្សាអប់រំកូនចៅរបស់ខ្លួន" ។ ("ក្រុមគ្រួសារៈ ការប្រកាសដល់ពិភពលោក" *លីអាហូណា* ខែ តុលា ឆ្នាំ 2004 ទំព័រ 49) ។

យើងត្រូវការចងចាំថា ការតាំងចិត្តទាំងមូលនៃមាតាភាព ហើយក្នុងការដាក់កូនៗជាកិច្ចការចម្បងអាចជារឿងលំបាក ។ តាមរយៈបទពិសោធន៍អស់បួនជំនាន់របស់ខ្ញុំផ្ទាល់ នៅក្នុងក្រុមគ្រួសាររបស់យើង ហើយតាមរយៈការពិភាក្សាជាមួយនឹងម្តាយដែលមានកូនវ័យក្មេងទាំងឡាយ នៅទូទាំងសាសនាចក្រ ខ្ញុំដឹងនូវអ្វីមួយពីសតិអារម្មណ៍របស់ម្តាយដែលរួមជាមួយនឹងការតាំងចិត្តរបស់នាងក្នុងការនៅផ្ទះជាមួយនឹងកូនតូចៗរបស់នាងនៅផ្ទះ ។ មានគ្រានៃសេចក្តីរីករាយយ៉ាងមហិមា ហើយនិងការបំពេញដ៏មិនគួរឱ្យជឿ ប៉ុន្តែក៏មានគ្រានៃស្មារតីដែលមិនគ្រប់គ្រាន់សំរាប់ការជ្រើសរើសដែលពួកនាងបានធ្វើ ។ នៅពេលខ្លះ សូម្បីតែស្វាមីក៏ហាក់ដូចជាមិនដឹងពីការពឹងផ្អែកទៅលើភរិយារបស់ពួកគេផងដែរ ។

ក្នុងនាមជាសាសនាចក្រមួយ យើងមានការគោរពយ៉ាងខ្លាំង ហើយមានអំណរគុណចំពោះមាតាទាំងឡាយ

ដែលមានកូនតូចៗ។ យើងចង់ឱ្យអ្នកសប្បាយ ហើយមានជោគជ័យនៅក្នុងក្រុមគ្រួសាររបស់អ្នក ហើយការអនុមតិ និងការគាំទ្រដែល អ្នកត្រូវការ ហើយនិងការសមនឹងទទួលបាន។ ដូច្នេះនៅថ្ងៃនេះ សូមឱ្យខ្ញុំសួរអ្នក ហើយឆ្លើយយ៉ាងខ្លី នូវសំណួរទាំងបួន។ ខណៈពេលដែលចម្លើយជាច្រើនហាក់ដូចជាសាមញ្ញ បើកិច្ចការសាមញ្ញត្រូវបានយកចិត្តទុកដាក់ នោះជីវិតរបស់ម្តាយមួយរូបជារង្វាន់ដ៏ថ្លៃថ្លាបំផុត។

សំណួរទីមួយ ៖ តើ *អ្នក* អាចធ្វើអ្វីក្នុងនាមជាម្តាយវ័យក្មេង ដើម្បីកាត់បន្ថយសម្ពាធ និងបង្កើនភាពរីករាយ នៅក្នុងគ្រួសាររបស់អ្នកកាន់តែខ្លាំងថែមទៀត?

ទីមួយ ដឹងថាភាពរីករាយនៃមាតាភាពកើតឡើងតាមឱកាសជាច្រើន។ មានពេលលំបាក ហើយពេលស្មុគស្មាញ។ ប៉ុន្តែក្នុងចំណោមឧបសគ្គទាំងឡាយនឹងមានឱកាសដ៏ចែងចាំងនៃសេចក្តីរីករាយ និងការពេញចិត្ត។ អ្នកនិពន្ធ អាន់ណា ខ្វិនឡេន បានរំលឹកយើងថាកុំឱ្យប្រញាប់ប្រញាល់ឱ្យឱកាសនេះកន្លងទៅឡើយ។ នាងបាននិយាយថា ៖ "កំហុសដ៏ធំជាងគេដែលខ្ញុំបានធ្វើ (ក្នុងនាមជាឪពុកម្តាយ) គឺជាកំហុសដែលយើងទាំងអស់គ្នាភាគច្រើនធ្វើ...។ ខ្ញុំមិនបានរស់ដោយមានឱកាសគ្រប់គ្រាន់នោះទេ។ ការណ៍នេះពិតជាច្បាស់ណាស់ឥឡូវនេះ នៅពេលដែលឱកាសនោះ បានកន្លងទៅបានថតតែនៅក្នុងរូបថត។ មានរូបថតមួយនៃកូនចៅបីនាក់របស់ខ្ញុំ... ដែលកំពុងអង្គុយនៅលើសំពត់ ក្រាលលើស្មៅក្រោមម្លប់ឈើ នៅរដូវក្តៅមួយ ដែលមានអាយុប្រាំមួយឆ្នាំ បួនឆ្នាំ និងមួយឆ្នាំ។ ហើយខ្ញុំប្រាថ្នាថាខ្ញុំអាចចងចាំនូវអ្វីដែលយើងបានបរិភោគ ហើយអ្វីដែលយើងនិយាយអំពី ហើយឥឡូវនេះអ្វីៗទាំងនោះរឹងមាំយ៉ាងណា ហើយមើលថាតើពួកគេមានទ្រង់ទ្រាយយ៉ាងម៉េច នៅពេលដែលពួកគេដេកនៅពេលយប់។ ហើយខ្ញុំប្រាថ្នាថាខ្ញុំមិនបានរវល់បែបនោះពេកទេ ក្នុងការទៅធ្វើកិច្ចការបន្ទាប់៖ អាហារពេលល្ងាច ងូតទឹក សៀវភៅ គ្រែ។ ខ្ញុំប្រាថ្នាថា ខ្ញុំបានលើកស្ទួយការធ្វើថែមបន្តិចទៀត ហើយបានទទួលលទ្ធផលតិចតួច" (*Loud and Clear* [ឆ្នាំ 2004] ទំព័រ 10-11)។

ទីពីរ សូមកុំដាក់កាលវិភាគរបស់អ្នកហួសកំណត់សំរាប់ខ្លួនរបស់អ្នក ឬកូនចៅរបស់អ្នក។ យើងរស់នៅក្នុងពិភពលោកដែលពោរពេញដោយជំរើស។ បើយើងមិនប្រុងប្រយ័ត្ន នោះយើងនឹងឃើញថា គ្រប់នាទីត្រូវបានបំពេញដោយព្រឹត្តិការ សង្គម ថ្នាក់ជាច្រើន ពេលហាត់ប្រាណ កក់ខ្លីប សៀវភៅអនុស្សាវរីយ៍ ការហៅរបស់សាសនាចក្រ តន្ត្រី កីឡា អ៊ីនធើណែត និងការបង្ហាញកម្មវិធីដែលយើងស្រឡាញ់តាមទូរទស្សន៍។ ម្តាយម្នាក់បានប្រាប់ខ្ញុំថា កូនៗរបស់នាងបានដាក់ 29 ការតាំងចិត្តជារៀងរាល់សប្តាហ៍៖ មេរៀនតន្ត្រី កាយវិទ្ធិ រាំរែក ការហាត់ល្បែង បោះជំរុំ បាល់ទាត់ សិល្បៈ ។ល។ នាងមានអារម្មណ៍ថាខ្លួនឯងដូចជាអ្នកបើកឡានស៊ីស្ទួលដូច្នោះ។ នៅទីបំផុត នាងបានរៀបចំការប្រជុំ ជាគ្រួសារ ហើយបានប្រកាសថា៖ "អ្វីៗដែលយើងត្រូវតែបញ្ឈប់ យើងគ្មានពេលវេលាសំរាប់ខ្លួនរបស់យើងទេ ហើយគ្មានពេលសំរាប់គ្នាឡើយ"។ ក្រុមគ្រួសារត្រូវការពេលវេលាដែលមិនមានរចនាសម្ព័ន្ធ នៅពេលដែលចំណងមិត្តភាព អាចត្រូវបានធ្វើឱ្យកាន់តែស៊ីជំរៅ ហើយមានការចិញ្ចឹមបីបាច់ដ៏ពិតប្រាកដដែលអាចធ្វើឡើង។ សូមចំណាយពេលដើម្បីស្តាប់ សើច ហើយលេងជាមួយគ្នា។

ទីបី ទោះបីជាអ្នកព្យាយាមបញ្ឈប់នូវការតាំងចិត្តបន្ថែម បងប្អូនស្រីទាំងឡាយ សូមស្វែងរកពេលវេលាខ្លះសំរាប់ខ្លួនរបស់អ្នក ដើម្បីបណ្តុះអំណោយទាន និងអត្ថប្រយោជន៍របស់អ្នក។ សូមជ្រើសរើសកិច្ចការមួយ ឬពីរដែលអ្នកចង់រៀន ឬធ្វើ ដែលនឹងធ្វើឱ្យជីវិតរបស់អ្នកលូតលាស់ ហើយចំណាយពេលសំរាប់ពួកគេ។ យើងមិនអាចដងទឹកចេញពីអណ្តូងដែលស្ងួតនោះទេ ហើយបើអ្នកមិនទុកពេលវេលាបន្តិចសំរាប់អ្វីដែលបំពេញកម្លាំងអ្នក នោះអ្នកនឹងមានតិច

ទៅៗដើម្បីឱ្យទៅអ្នកដទៃ សូម្បីតែឱ្យទៅកូនចៅរបស់អ្នក។ សូមជៀសវាងរាល់ការប្រើប្រាស់គ្រឿងញៀន សូមកុំគិតដោយយល់ខុសថា គ្រឿងញៀនទាំងនោះនឹងជួយអ្នកទទួលបានជោគជ័យថែមទៀតឡើយ។ ហើយសូមកុំបណ្តោយឱ្យខ្លួនរបស់អ្នកត្រូវធ្លាក់ចូលទៅក្នុងការចំណាយពេលវេលាឥតប្រយោជន៍ គំនិតចំពោះកិច្ចការជាច្រើនដូចជា កម្មវិធីទូរទស្សន៍ ស្ទូប អូភើរ៉ាស ឬការស្វែងរកតាមអ៊ីនធើណែត។ សូមងាកទៅរកព្រះអម្ចាស់នៅក្នុងសេចក្តីជំនឿ ហើយអ្នកនឹងដឹងនូវអ្វីដែលអ្នកត្រូវធ្វើ ហើយរបៀបដែលអ្នកអាចធ្វើកិច្ចការនោះបាន។

ទីបួន សូមអធិស្ឋាន សិក្សា ហើយបង្រៀនដំណឹងល្អ។ សូមអធិស្ឋានយ៉ាងស៊ីជំរៅអំពីកូនចៅរបស់អ្នក និងអំពីតួនាទីរបស់អ្នកក្នុងនាមជាម្តាយមួយរូប។ ឪពុកម្តាយអាចផ្តល់ឱ្យនូវការអធិស្ឋានដ៏ពិសេស និងអស្ចារ្យ ពីព្រោះពួកគាត់កំពុងអធិស្ឋានទៅព្រះវរបិតាដ៏នៅអស់កល្បជានិច្ចនៃយើងទាំងអស់គ្នា។ នេះគឺជាអំណាចដ៏មហិមាដែលបាននិយាយយ៉ាងច្បាស់ថា: "យើងគឺជាឪពុកម្តាយដែលមាននូវការទទួលខុសត្រូវលើកូនចៅរបស់ទ្រង់ ឱ! ព្រះវរបិតា សូមជួយយើងចិញ្ចឹមពួកគេតាមដែលទ្រង់មានព្រះទ័យចង់ឱ្យពួកគេត្រូវបានចិញ្ចឹម"។

សំណួរទីពីរ: តើយើងស្វាមីអាចធ្វើអ្វីបន្ថែមទៀត ដើម្បីជួយឧបត្ថម្ភដល់ភរិយារបស់គាត់ ជាម្តាយនៃកូនៗរបស់ពួកគេ?

ទីមួយ សូមបង្ហាញការថ្លែងអំណរគុណបន្ថែមទៀត ហើយសូមផ្តល់ការគាំទ្រថែមទៀត សំរាប់អ្វីដែលភរិយារបស់អ្នកធ្វើជារៀងរាល់ថ្ងៃ។ សូមកត់សំគាល់អ្វីៗទាំងអស់ ហើយសូមនិយាយពាក្យថាអរគុណ---ឱ្យបានញឹកញាប់។ សូមដាក់កាលវិភាគនៅជាមួយគ្នានៅពេលល្ងាច គឺតែអ្នកទាំងពីររូបប៉ុណ្ណោះ។

ទីពីរ សូមមានពេលវេលាជាទៀងទាត់ជាមួយនឹងភរិយារបស់អ្នកអំពីសេចក្តីត្រូវការរបស់កូនៗរបស់អ្នក ហើយអ្វីដែលអ្នកអាចធ្វើដើម្បីជួយ។

ទីបី សូមផ្តល់ឱ្យភរិយារបស់អ្នកមួយ "ថ្ងៃពីមុន" នៅពេលឥឡូវនេះ និងពេលអនាគត។ សូមធ្វើកិច្ចការផ្ទះ ហើយផ្តល់ឱ្យភរិយារបស់អ្នកនូវការសំរាកពីការទទួលខុសត្រូវជាប្រចាំរបស់នាង។ ការធ្វើការគ្រប់គ្រងមួយរយៈនឹងបន្ថែមនូវ អំណរគុណរបស់អ្នកនូវអ្វីដែលភរិយារបស់អ្នកធ្វើជារៀងរាល់ថ្ងៃ។ អ្នកប្រហែលជាធ្វើកិច្ចការលើកទុកដាក់បត់បែន និងឱនចុះជាច្រើន!

ទីបួន ត្រឡប់មកពីធ្វើការវិញ ហើយធ្វើតួនាទីយ៉ាងសកម្មជាមួយនឹងគ្រួសាររបស់អ្នក។ សូមកុំដាក់ការងារមិត្តភក្តិ ឬកីឡាពីមុខនៃការស្តាប់ចំពោះ ការអធិស្ឋានជាមួយ និងការបង្រៀនកូនចៅរបស់អ្នកឡើយ។

សំណួរទីបី។ តើក្មេងៗអាច និងកូនតូចៗអាចធ្វើអ្វីបានខ្លះ? ឥឡូវនេះអ្នកដែលជាកូន សូមស្តាប់ខ្ញុំ ពីព្រោះមាននូវរឿងដ៏សាមញ្ញដែលអ្នកធ្វើដើម្បីជួយម្តាយ។

អ្នកអាចរើសល្បែងលេងរបស់អ្នកទុក នៅបន្ទាប់ពីអ្នកលេងជាមួយនឹងពួកគេរួចហើយ ហើយនៅពេលអ្នកធំឡើងបន្តិច អ្នកអាចរៀបចំគ្រែដេករបស់អ្នក ជួយលាងចាន និងធ្វើមុខងារផ្សេងៗទៀត---ដោយពុំចាំបាច់ឱ្យប្រាប់ឡើយ។

អ្នកអាចនិយាយថា: "អរគុណ" ឱ្យបានកាន់តែញឹកញាប់ នៅពេលដែលអ្នកបរិភោគអាហារដ៏ឆ្ងាញ់រួច នៅពេលដែលរឿងព្រេងត្រូវបានអានឱ្យអ្នកស្តាប់នៅពេលចូលដេក ឬដាក់សំលៀកបំពាក់ដែលស្អាតនៅថតទូ។

យើងទាំងអស់គ្នាភាគច្រើន អាចឱបម្តាយរបស់អ្នកឱ្យបានញឹកញាប់ ហើយប្រាប់នាងថា អ្នកស្រឡាញ់នាង។

សំណួរចុងក្រោយៈ តើសាសនាចក្រអាចធ្វើអ្វីបាន?

មានអ្វីៗជាច្រើនដែលសាសនាចក្រផ្ដល់ឱ្យដល់ម្ដាយ និងគ្រួសារទាំងឡាយ ប៉ុន្តែសំរាប់គោលបំណងរបស់ខ្ញុំនៅថ្ងៃនេះ ខ្ញុំសូមស្នើឱ្យប៊ីស្សព និងសមាជិកក្រុមប្រឹក្សាវួដ សូមមើលជាពិសេស ហើយពិចារណាពីពេលវេលា និងធនធានដែលត្រូវការចំពោះម្ដាយវ័យក្មេង និងក្រុមគ្រួសាររបស់ពួកគេ។ សូមស្គាល់ពួកគេ ហើយសូមវាងវៃចំពោះអ្វីដែលអ្នកសុំពួកគេឱ្យធ្វើនៅក្នុងពេលនេះនៃជីវិតរបស់ពួកគេ។ ពាក្យទូន្មានរបស់អាលម៉ាចំពោះហេលេមិន ជាកូនប្រុសរបស់គាត់ក៏អនុវត្ត ចំពោះយើងសព្វថ្ងៃនេះដែរថាៈ "មើលចុះឪពុកប្រាប់កូនថា ដោយកិច្ចការតូចតាច និងងាយទើបនាំឱ្យកើតកិច្ចការដ៏ធំៗបាន" (អាលម៉ា 37:6)។

ខ្ញុំសង្ឃឹមថា បងប្អូនស្រីជាទីស្រឡាញ់របស់ខ្ញុំទាំងអស់ ទាំងរៀបការរួច និងនៅលីវ សូមកុំឆ្ងល់ថាតើបងប្អូនមានតម្លៃចំពោះព្រះនេត្រនៃព្រះអម្ចាស់ និងចំពោះពួកអ្នកដឹកនាំនៃសាសនាចក្រឬអត់។ យើងស្រឡាញ់បងប្អូនទាំងអស់គ្នា។ យើងគោរពបងប្អូន ហើយថ្លែងអំណរគុណចំពោះឥទ្ធិពលរបស់អ្នក នៅក្នុងការថែរក្សាក្រុមគ្រួសារ និងជួយឱ្យមានការរីកចំរើន និងសុពលភាពខាងវិញ្ញាណនៃសាសនាចក្រ។ ចូរយើងចងចាំថាៈ "គ្រួសារជាផ្នែកសំខាន់មួយនៃផែនការរបស់ព្រះដ៏បង្កបង្កើតសំរាប់គោលដៅដ៏អស់កល្បជានិច្ចនៃកូនចៅរបស់ព្រះអង្គ" (ក្រុមគ្រួសារ ៈ ការប្រកាសដល់ពិភពលោក")។ ព្រះគម្ពីរ និងការបង្រៀនទាំងឡាយនៃព្យាការី និងពួកសាវក ជួយសមាជិកក្រុមគ្រួសារទាំងអស់រៀបចំខ្លួន ដើម្បីរស់នៅជាមួយគ្នាឥឡូវនេះ និងអស់កល្បជានិច្ច។ ខ្ញុំសូមអធិស្ឋានថាព្រះនឹងបន្តប្រទានពរជ័យដល់ស្ត្រីទាំងឡាយនៃសាសនាចក្រ ហើយនិងសុភមង្គលនៅក្នុងតួនាទីដ៏ពិសិដ្ឋរបស់ពួកគេក្នុងនាមជាបុត្រីនៃព្រះ។

ឥឡូវនេះ ខ្ញុំសូមបិទ ខ្ញុំចង់បន្ថែមទីបន្ទាល់របស់ខ្ញុំពីការហៅឱ្យធ្វើជាព្យាការីរបស់ប្រធាន ម៉ុសុន។ ខ្ញុំបានស្គាល់លោកតាំងពីលោកមានអាយុ 22 ឆ្នាំ ហើយខ្ញុំមានអាយុ 21 ឆ្នាំ។ នោះគឺ 58 ឆ្នាំ។ ខ្ញុំបានឃើញនូវព្រះហស្តនៃព្រះអម្ចាស់រៀបចំលោក សំរាប់ថ្ងៃនេះដើម្បីធ្វើជាអធិបតីលើសាសនាចក្រ ជាព្យាការី និងជាប្រធានរបស់យើង។ ហើយខ្ញុំសូមបន្ថែមទីបន្ទាល់របស់ខ្ញុំជាមួយនឹងអ្នកដទៃផ្សេងទៀត ដែលបានធ្វើទីបន្ទាល់នៅក្នុងសន្និសីទនេះពីការហៅពិសិដ្ឋរបស់លោក ជាប្រធាននៃសាសនាចក្រ និងបន្ថែមនូវទីបន្ទាល់របស់ខ្ញុំជាមួយនឹងអ្នកដទៃទៀតផងដែរថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយនេះគឺជាសាសនាចក្ររបស់ទ្រង់។ យើងកំពុងតែធ្វើកិច្ចការរបស់ទ្រង់ ជាអ្វីដែលបានធ្វើទីបន្ទាល់នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។